# សិក្សាអំពីដើមកំណើតឈ្មោះខេត្តបាត់ដំបង

មានមតិជាច្រើន និងពិសេសគឺរឿងព្រេងបានរៀបរាប់អំពីដើមកំណើតឈ្មោះខេត្តបាត់ដំបង ដែលស្ថិតនៅភាគពាយ័ព្យប្រទេសកម្ពុជាសព្វថ្ងៃ។ ហេតុអ្វីបានជាហៅឈ្មោះបាត់ដំបង?

ពិតណាស់ប្រជាជនខ្មែរសព្វថ្ងៃ ពេលនិយាយដល់ឈ្មោះខេត្តបាត់ដំបង គេតែងនឹកដល់រឿងព្រេងលោកតាដំបងក្រញូង ដែលជាហេតុនាំអោយគេហៅតំបន់ ឬខេត្តនេះថា បាត់ដំបង។ តាមរយៈសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៩[១] រៀបរាប់អំពីរឿងប្រាសាទព្រហ្មកិលនៅខេត្តសៀមរាប។ នេះជាគឺជារឿងព្រេងដែលមានប្រភពមិនច្បាស់លាស់ និងអាចលេចឡើងក្នុងសតវត្សទី១៨ ឬ១៩ ដែលគេប្រឌិតឡើងដើម្បីបង្ហាញអំពីឈ្មោះរបស់ខេត្តនេះតែប៉ុណ្ណោះ។ យើងក៏មិនមានភស្តុតាងជាក់លាក់សម្រាប់បកស្រាយឱ្យច្បាស់លាស់អំពីដើមកំណើតរបស់ឈ្មោះនេះដែរ។ ប៉ុន្តែបើយើងពិនិត្យមើលលើស្ថាននាមបុរាណដែលមានក្នុងសិលាចារឹកមួយចំនួន និងប្រៀបធៀបជាមួយនឹងស្ថានាមដទៃទៀតក្នុងតំបន់ផ្សេងៗ ឬក្នុងប្រទេសកម្ពុជា យើងនឹងអាចទាញយកសេចក្តីសន្និដ្ឋានមួយបានអំពីឈ្មោះដើមរបស់តំបន់ឬខេត្តនេះ។

ការសិក្សាពាក្យក្នុងសិលាចារឹក មានការឱ្យគំនិតខុសគ្នារវាងអ្នកស្រាវជ្រាវ។ លោក Aymonier[២] បានផ្តល់នូវគំនិតមួយដែលទាក់ទងនឹងពាក្យ **តំវ្វង** (taṃvvaṅ) ដែលរកឃើញជាលើកដំបូងក្នុងសិលាចារឹកប្រាសាទភ្នំព្រះនេត្រព្រះ គឺសិលាចារឹក K.215(រូបលេខ២)។[៣] លោកបានសន្និដ្ឋានថា ពាក្យ **តំវ្វង** អាចសរសេរជា **តំបូង** មានន័យថា ព្រៃដំបូងដែលអាចក្លាយជាឈ្មោះខេត្តសព្វថ្ងៃ ហៅថា **ព្រះដំបង**។ ពាក្យ **តំវ្វង** នេះយើងឃើញមានជាលើកទី

---

[១] https://khmer-lfrd.com

[២] E. Aymonier 1901:322

[៣] G. Cœdès 1951:34-36

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

១ក្នុងសិលាចារឹកភ្នំព្រះនេត្រព្រះ ដែលបានរៀបរាប់អំពីបុរសម្នាក់ឈ្មោះ **លោញ អប** នៅឯព្រៃ**តំរូង** បានមកទិញដីផ្តល់ឱ្យបុរសម្នាក់ទៀតឈ្មោះ **លោញ បិត្ត ព្រៅ** ដើម្បីកសាងអាស្រម នៅក្នុងឆ្នាំ៨៦០ស.ក (៩៣៨គ.ស)។[៤] ប៉ុន្តែ **លោញ អប** បានស្លាប់បាត់ក្នុងឆ្នាំ៨៧១ ស.ក (៩៤៩គ.ស) ការសាងសង់អាស្រមនោះក៏បានផ្អាក។ សិលាចារឹកនេះបានបង្ហាញថា **លោញ អប** ជាមនុស្សមកពី ឬរស់នៅឯ **ព្រៃតំរូង** ប៉ុន្តែមិនបានបញ្ជាក់ថា **ព្រៃ តំរូង**នោះស្ថិតនៅតំបន់ណាទេ។

សិលាចារឹកមួយផ្សេងទៀត រកឃើញនៅភូមិតាងើន[៥] ចម្ងាយប្រហែល២០គ.ម ខាងលិចក្រុងបាត់ដំបង គឺសិលាចារឹក K.212។[៦] ក្នុងអត្ថបទសិលាចារឹកនោះ និយាយអំពីការរំលឹកដល់ដង្វាយជាខ្ញុំបំរើ និងដីធ្លីក្រោមការត្រាស់បង្គាប់របស់ព្រះបាទសូរ្យវរ្ម័នទី១ ក្នុងឆ្នាំ ៩៤៩ស.ក (១០២៧គ.ស) ដល់ប្រាសាទឈ្មោះ **ជ័យក្សេត្រ** (វត្តបាសែត)។ ក្នុងការសង់គោល(ព្រំដី)នោះ មានដីស្រែមួយកន្លែងដែលជាកម្មសិទ្ធរបស់បុរសម្នាក់ ឈ្មោះ **លោញ នរាយ** នៅឯ **ព្រៃ តំរូង**។ នេះអាចបញ្ជាក់ថា **ព្រៃ តំរូង** អាចមានទីតាំងស្ថិតនៅក្បែរប្រាសាទវត្តបាសែត ឬក្រុងបាត់ដំបងសព្វថ្ងៃ។ សិលាចារឹក១ផ្សេងទៀត K.207 នៅប្រាសាទវត្តបាសែតតែម្តង និយាយអំពីការឱ្យដង្វាយដល់ប្រាសាទឈ្មោះ **ជ័យក្សេត្រ** ជាវត្ថុ ដីស្រែ និងខ្ញុំបំរើជាច្រើន។ លើសពីនេះមានរាយនាមមន្ត្រីដែលគ្រប់គ្រងនៅតាមតំបន់ផ្សេងៗជាច្រើន ក្នុងនោះមានម្នាក់ឈ្មោះ **កំស្តេង មត ព្រៃ ខ្វាញ កុតាស ព្រៃ តំរូង**។ ផ្ទុយពីមតិនេះ លោកស្រី Savaros[៧] បានឱ្យន័យពាក្យ **តំរូងឬតំរុង** ដែលមានក្នុងសិលាចារឹក K.207 (បន្ទាត់ទី៥៦) និង K.215 ថាជាប្រភេទរុក្ខជាតិ ដែលយើងហៅសព្វថ្ងៃថា **ទំពូងឬដើមទំពូង**

---

[៤] សុខ កែវ សុវណ្ណារ៉ា ២០២១:២

[៥] E. Lunet de Lajonquière 1911:439

[៦] G. Cœdès 1951:29-33

[៧] Savasos Pou, 1992:213

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

គឺដូចគ្នានឹងយោបល់លោក ឡុង សៀម[៨] ដែលយល់ថាពាក្យ **តំរ្វង** ជាប្រភេទរុក្ខជាតិឈ្មោះ **ទំពូង** ឧទាហរណ៍តាមរយៈសិលាចារឹក K.600[៩] មានពាក្យ **បិង តំរ្វង** (បឹងទំពូង) (រូបលេខ៣)។ ប៉ុន្តែលោកស្រីបានឱ្យន័យទៅលើពាក្យ **តំបោង** ក្នុងសិលាចារឹក K.207 ដដែល ក្នុងបន្ទាត់ទី៥១ ថាជាពាក្យ ដំបូង (ទី១) ត្បូង ឬក្បាល (ទី២) និងតំបង ដែលអាចជាឈ្មោះដើមរបស់ខេត្តបាត់ដំបងសព្វថ្ងៃ (ទី៣)។[១០] បន្ថែមលើនេះ ក្នុងសិលាចារឹក K.44[១១] (បន្ទាត់ទី១១) មានពាក្យ **តំបោង្ស** (ស្រេ អំរិ ទិក ហេរ លោះ ប្រៃ តំបោង្ស) និង K.158 (បន្ទាត់ទី២៦) មានពាក្យ **តំបូង** (កញ្ជេ ផ្ទាំង តំបូង)។

នេះជាចំណុចផ្ទុយគ្នាលើពាក្យតែមួយ ចំពោះមតិអ្នកស្រាវជ្រាវទាំងនេះ។ ដូចនេះជាដំបូងយើងត្រូវលើកយកពាក្យ ទាំង២ គឺ**តំរ្វង និងតំបូង** មកសិក្សាសិន។ ពាក្យទាំង២ នេះមិនសូវមានក្នុងសិលាចារឹកខ្មែរបុរាណប៉ុន្មានទេ។ ពាក្យ **តំរ្វង** មានវត្តមានក្នុងសិលាចារឹក ៣ផ្សេងគ្នា (K.207 K.212 និង K.215) ហើយជាស្ថាននាម ដែលស្ថិតនៅក្បែរតំបន់បាត់ដំបងសព្វថ្ងៃ (រូបលេខ១)។ រីឯពាក្យ **តំបូងឬតំបោង** មានវត្តមានតែ២ដង ក្នុងសិលាចារឹក (K.207 និង K.158)។ សិលាចារឹក K.158 រកឃើញនៅទួលប្រាសាទក្នុងស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ[១២] ដែលមានពាក្យ **តំបូង** ភ្ជាប់ជាមួយនឹងប្រភេទផ្ទាំងម្យ៉ាង ដែលលោក Jenner[១៣]បានបកស្រាយថា ជាប្រភេទផ្ទាំងមូល (ផ្ទាំងតំបូង) ម្យ៉ាង។ ក្នុងសិលាចារឹក K.207 មានពាក្យ២ ដែលគេសរសេរក្នុងអត្ថបទតែមួយ គឺពាក្យ **តំបោង** ក្នុងជួរបន្ទាត់ទី៥១

---

[៨] ឡុង សៀម (១៩៩៧:៧២)

[៩] G. Cœdès 1942:22

[១០] Savasos Pou 1992:212

[១១] G. Cœdès 1942:103

[១២] E. Aymonier 1900:379

[១៣] Philip N. Jenner 2009:191

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

( កំស្តេង ប្រែ តំបោង ត្រូច វល) និងពាក្យ **តំរ្វង** ក្នុងជួរបន្ទាត់ទី៥៦ (កំស្តេង មត ប្រែ ខ្ញោញ កូតាស ប្រែ តំរ្វង)។ តើពាក្យទាំងពីរក្នុងសិលាចារឹកតែ១នេះ មានន័យខុសគ្នាឬយ៉ាងណា?

ចំណុចនេះវាពិបាកក្នុងការបកស្រាយណាស់។ វាអាចជាពាក្យតែមួយ តែដោយការសរសេរមានការខុសឆ្គងឬក៏ជាពាក្យ២ផ្សេងគ្នាដូចអ្នកស្រី Savaros បានបរិយាយ។ យើងឃើញមានចំណុចបែបនេះច្រើនក្នុងសិលាចារឹកបុរាណខ្មែរ ឧទាហរណ៍ ពាក្យ **ភិមាល័យ** (ក្នុងសិលាចារឹកពោធិរោងដាង)[១៤] និង **ភិមល័យ** (ក្នុងសិលាចារឹកគោកចាន់ K.340)។[១៥]

បញ្ហាចោទគឺថា តើពាក្យ **តំរ្វង**ឬពាក្យ **តំបោង** គួរជាពាក្យ ដែលអាចក្លាយមកជាពាក្យបាត់ដំបងសព្វថ្ងៃ? ពាក្យ **តំរ្វង** មានក្នុងសិលាចារឹក៣ ដែលមានទីតាំងស្ថិតនៅក្បែរ ឬជុំវិញក្រុងបាត់តំបង ដូចជាក្នុងសិលាចារឹក K.207 K.212 និង K.215។ រីឯ ពាក្យ **តំបោង** មានតែម្តងក្នុងសិលាចារឹក K.207ដែរ។ ក្នុងករណីមួយ ប្រសិនបើពាក្យ **តំបោង** ជាកំហុសឆ្គងក្នុងការសរសេរក្នុងសិលាចារឹក K.207 បន្ទាត់ទី៥១ ពោលគឺវាអាចជាពាក្យ **តំរ្វង** ក្នុងបន្ទាត់ទី៥៦ដែរ។ វាអាចចំណុចរួមមួយដែលយើងគួរទាញសេចក្តីសន្និដ្ឋានបានថា ពាក្យ **តំរ្វង** ជាឈ្មោះតំបន់មួយ ហើយក្លាយមកជាពាក្យ **ព្រះដំបង** ដូចដែលលោក Aymonier បានគិត។ ចំណុចនេះ យើងអាចប្រៀបធៀបមកស្ថាននាមវិទ្យាផ្សេងទៀត ដូចជាឈ្មោះស្រុកមង្គលបុរី ដែលដើមឡើយត្រូវបានគេហៅថា មង្គលបុរៈ មានចារក្នុងសិលាចារឹកប្រាសាទវត្តបាសែត (K.205:18) និង (K.206:37)[១៦] ជាដើម។

ដូចនេះ យើងអាចទាញយកសេចក្តីសន្និដ្ឋានមួយបានថា ពាក្យ **ព្រៃតំរ្វង** ជាពាក្យបុរាណសម្គាល់លើតំបន់មួយនៅជុំវិញទីរួមខេត្តបាត់ដំបងសព្វថ្ងៃ។ ក្រោយមក ពាក្យនេះ

---

[១៤] សុខ កែវ សុវណ្ណារ៉ា និង ឈូក សុម៉ាឡា, (២០២០:៩)

[១៥] G. Cœdès, (1954:81-82)

[១៦] G. Cœdès, (1951:3-17),

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

តាមការនិយាយ ជាសូរសៀងរបស់មនុស្សពីសម័យកាលមួយ ទៅសម័យកាលមួយ អាចក្លាយជាពាក្យ ព្រះដំបង ដែលគេនៅប្រើប្រាស់រហូតដល់ចុងសតវត្សទី១៩។ ក្នុងសម័យដែលបាត់ដំបងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ត្រកូលអ័យវង្ស ពាក្យនេះត្រូវបានប្រើជាអត្តសញ្ញាណនៃកាក់ (រូបលេខ២)[១៧]ដែលបោះពុម្ពដោយក្រុមគ្រួសារ ឧញ៉ា បែន និងសៀមដើម្បីប្រើប្រាស់ក្នុងការដោះដូរ ជំនួញ និងសួយសារអាករដល់ស្តេចសៀម។ រីឯឈ្មោះ **ព្រះដំបង** គឺស្តេចរាមាទី១បានកំណត់ឱ្យហៅឈ្មោះភូមិសង្កែថាជា **ព្រះដំបង**។[១៨] ចំណុចនេះប្រហែលស្តេចសៀមបានស្គាល់ពាក្យ **ព្រះដំបង** ច្បាស់លាស់ (ដែលខ្មែរបានប្រើប្រាស់ ឬនិយាយប្រចាំថ្ងៃ) ឬក៏ជាការស្នើរបស់គ្រួសារឧញ៉ាបែន ដើម្បីជាអត្តសញ្ញាណប្រចាំតំបន់ដែលខ្លួនគ្រប់គ្រង។ វាមិនមែនជាពាក្យដែលស្តេចសៀមបង្កើតដោយអង្គឯងដើម្បីហៅតំបន់នោះថា **ព្រះដំបង**ទេ។ ពាក្យ **ព្រះដំបង** ជាពាក្យដែលត្រូវបានខ្មែរតំបន់នោះប្រើក្នុងសម័យកណ្តាល (ក្រោយអង្គរ) អាចក្លាយមកពីពាក្យបុរាណ (សម័យអង្គរ) **តំរ៉ូង**។

ដូចនេះ យើងអាចឱ្យសម្មតិកម្មបានថា តំបន់បាត់ដំបងសព្វថ្ងៃ បានក្លាយមកពីពាក្យបុរាណ **(ប្រែ) តំរ៉ូង < ព្រះដំបង <បាត់ដំបង**។

---

[១៧] Howard A. Daniel III, (2012:38)

[១៨] https://km.wikipedia.org/wiki/ខេត្តបាត់ដំបង

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា




រូបលេខ១ ផែនទីបង្ហាញពីទីតាំងសិលាចារឹក



រូបលេខ២៖ សិលាចារឹកប្រាសាទភ្នំព្រះនេត្រព្រះ (K.215)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា



រូបលេខ១៣៖ សិលាចារឹកប្រាសាទវត្តបាសែត (K.207)




រូបលេខ១៤៖ កាក់មានពាក្យ ព្រះដំបង (១៨៨៥)

អត្ថបទដោយ៖ សុខ កែវ សុវណ្ណារ៉ា

# ឯកសារយោង

សុខ កែវ សុវណ្ណារ៉ា.

២០២១. *ប្រាសាទភ្នំព្រះនេត្រព្រះ*, ក្នុង AMS ភ្នំពេញ។

សុខ កែវ សុវណ្ណារ៉ា និង ឈូក សុម៉ាឡា.

២០២០. *សិលាចារឹកថ្មីនៅប្រាសាទពោធិពោងដាង*, ក្នុងអត្ថបទស្រាវជ្រាវថ្មី និងគួរពិចារណា, លេខ២៤, សៀមរាប។

ឡុង សៀម.

១៩៩៧. *ស្ថាននាមវិទ្យាខ្មែរ*, ពុទ្ធសាសនបណ្ឌិត, ភ្នំពេញ។

E. Aymonier.

1900. *Le Cambodge: Le Reyaume Actuel*, Tome I, Paris.

E. Aymonier.

1901. *Le Cambodge: Les Provinces Siamoises*, Tome II, Paris.

E. Lunet de Lajonquière.

1911:439. *Inventaire Descriptif des Monuments du Cambdoge*, Tome III, PEFEO, Paris.

G. Cœdès.

1942. *Inscription du Cambodge*, Volume II, Hanoi.

G. Cœdès.

1951. *Inscription du Cambodge*, Volume III, Paris.

G. Cœdès.

1954. *Inscription du Cambodge*, Volume VI, Paris.

Howard A. Daniel III.

2012. *Cambodian Coins and Currency*, Vietnam.

https://km.wikipedia.org/wiki/ខេត្តបាត់ដំបង

https://khmer-lfrd.com

**Philip N. Jenner.**

2009. *A Dictionary of Angkorian Khmer*, The Australia National University, Australia.

Savasos Pou.

1992. *An Old Khmer-French-English Dictionary*, Cedoreck, Paris.